**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ១៨៥ ប្រកា កសក

# ប្រកាស

## ស្តីពី

## លក្ខន្តិកៈគំរូ និងបទបញ្ជាផ្ទៃក្នុងគំរូសម្រាប់សហគមន៍កសិកម្ម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៨ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគមន៍កសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ១៧៩ អនក្រ.បក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម ចំណុះអគ្គនាយកដ្ឋានកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញប្រកាសលេខ១០៩ ប្រក.កសក.ប ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាន និងមន្ទីរពិសោធន៍ជាតិកសិកម្មក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម
- បានឃើញប្រកាសលេខ២២០ ប្រក.កសក.ប ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរកសិកម្មរាជធានី ខេត្ត
- បានឃើញប្រកាសលេខ០៩០ ប្រក.កសក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មក្រោមឱវាទអគ្គនាយកដ្ឋានកសិកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់នូវលក្ខន្តិកៈគំរូនិងបទបញ្ជាផ្ទៃក្នុងគំរូសម្រាប់សហគមន៍កសិកម្ម ដូចមានភ្ជាប់ជាឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ២.-**

ដើម្បីទទួលបាននីត្យានុកូលភាព ពល់សហគមន៍កសិកម្មត្រូវរៀបចំឱ្យមានលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនស្របតាមស្ថានភាពជាក់ស្តែងដោយអនុលោមតាមលក្ខន្តិកៈគំរូ និងបទបញ្ជាផ្ទៃក្នុងគំរូដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ៣.-**

លក្ខន្តិកៈរបស់សហគមន៍កសិកម្ម ត្រូវភ្ជាប់ជាចាំបាច់នូវស្លាកសញ្ញាសម្គាល់សហគមន៍កសិកម្មដោយអនុលោមតាមគំរូស្លាកសញ្ញាសម្គាល់សហគមន៍កសិកម្មកម្ពុជា និងមានឈ្មោះរបស់សហគមន៍កសិកម្មសាមីស្ថិតនៅខាងក្រោមស្លាកសញ្ញាសម្គាល់។

គំរូស្លាកសញ្ញាសម្គាល់សហគមន៍កសិកម្ម ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៣នៃប្រកាសនេះ។

**ប្រការ៤.-**

សហគមន៍កសិកម្ម មានសិទ្ធិបង្កើត និងប្រើប្រាស់ត្រាសម្គាល់សហគមន៍កសិកម្មលើឯកសារពាក់ព័ន្ធផ្លូវការរបស់ខ្លួនដោយអនុលោមតាមច្បាប់ស្តីពីសហគមន៍កសិកម្ម។

**ប្រការ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានកសិឧស្សាហកម្ម ប្រធាននាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត និងសហគមន៍កសិកម្ម ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-គ្រប់សាលារាជធានី ខេត្ត
-ដូចប្រការ ៦
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី៣ នៃប្រកាសលេខ......១៨៥..........ប្រក.កសក ចុះថ្ងៃទី.១៨..........ខែ.ឧសភា.......ឆ្នាំ២០១៦
ស្តីពីលក្ខន្តិកៈគំរូ និងបទបញ្ជាផ្ទៃក្នុងគំរូសម្រាប់សហគមន៍កសិកម្ម

## គំរូស្លាកសញ្ញាសម្គាល់សម្រាប់សហគមន៍កសិកម្ម

**សហគមន៍កសិកម្ម**...............................................

**១. ពណ៌ចំនួនប្រាំពីរ** ៖ តំណាងឱ្យគោលការណ៍គ្រឹះទាំងប្រាំពីររបស់សហគមន៍កសិកម្ម

**២. រូបមនុស្សបីនាក់** ៖ តំណាងឱ្យបុរស នារី និងយុវជន ចាប់ដៃគ្នាសាមគ្គីយ៉ាងស្អិតរមួត ដើម្បីអភិវឌ្ឍន៍សហគមន៍កសិកម្មរបស់ខ្លួន

**៣. ពណ៌បៃតង** ៖ តំណាងឱ្យវិស័យកសិកម្ម

**៤. ពណ៌ខៀវ** ៖ តំណាងឱ្យទឹកស្រោចស្រព

**៥. ស.ក.ក** ៖ អក្សរកាត់ជាភាសាខ្មែរ

**៦.**CAC ៖ CAMBODIA AGRICULTURAL COOPERATIVES

**៧.សហគមន៍កសិកម្ម**..................៖ឈ្មោះរបស់សហគមន៍កសិកម្មសាមីដែលត្រូវបំពេញ។